


**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ២៣

ទោះបីជាមានការឈប់សម្រាកបុណ្យជាតិចំនួនពីរថ្ងៃក្នុងសប្តាហ៍នេះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សីចំនួនពីររូប និងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ហើយបានចាប់ផ្តើមស្តាប់សក្ខីកម្មរបស់សាក្សីទី៣ ផងដែរ ក្នុងអំឡុងពេលនៃសវនាការរយៈពេលបីថ្ងៃ។ លោក **កែវ លឿ** អ្នកស្រី **គង់ សៀក** និងលោក **សែម ហឿន** ទាំងអស់គ្នាសុទ្ធតែជាសមាជិករបស់កងទ័ពបដិវត្តន៍កម្ពុជា ហើយពួកគាត់បានផ្តល់សក្ខីកម្មស្តីពីការបោសសម្អាតកម្មាភិបាលភូមិភាគឧត្តរ ដែលមកពីកងពលយោធានានា និងការចាត់តាំងការងាររបស់ពួកគេនៅការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ នៅថ្ងៃអង្គារ និងថ្ងៃពុធ នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានងាកត្រឡប់ទៅផ្តោតលើផ្នែកជំនុំជម្រះមុនៗ ស្តីពីការរដ្ឋានការងារ១មករា ដែលស្ថិតក្នុងខេត្តកំពង់ធំ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សី លោក **យាន លន់** ដែលជាកម្មករ និងជាឈ្លបនៅក្នុងការដ្ឋាននោះផងដែរ។ លោកចៅក្រម **ហ្សង់ ម៉ាកឡាវែញ** (**Jean-Marc Lavergne**) បានធ្វើអន្តរាគមន៍ចំនួនពីរដង នាសប្តាហ៍នេះ ក្នុងអំឡុងពេលនៃការសួរដេញដោលសាក្សី **កែវ លឿ** និង **គង់ សៀក** គឺនៅពេលដែលក្រុមការពារក្តីឲ្យលោក **នួន ជា** បានចោទសួរសំណួរជាក់លាក់ជាច្រើនដោយមិនមានការយោងទៅលើឯកសារណាមួយដើម្បីធ្វើជាការសម្អាងឡើយ។ លោកចៅក្រម ក៏បានក្រើនរម្លឹកដល់មេធាវីរបស់លោក **នួន ជា** កុំអោយប្រើប្រាស់ភស្តុតាងដែលទទួលបានមកពីការធ្វើទារុណកម្ម ក៏ប៉ុន្តែ បញ្ហានេះនៅតែបន្តកើតមានសាឡើងវិញ និងមានភាពចម្រូងចម្រាសគ្នា ដោយសារតែភាគីទាំងអស់ទន្ទឹមរង់ចាំនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលអូសបន្លាយពេលដ៏វែងលើបញ្ហានេះ។

* របាយការណ៍នេះ ត្រូវបានសរសេរដោយ លៀ ហ៊ូប៊ើ (Lea Huber), ម៉ាលេនី ហៃដ៍ (Melanie Hyde), លី ហួតផេង, ដានៀល ម៉ាតថេស៍ (Daniel Mattes), តាយ លីណា, ថោង វិច្ចិកា, កាធើរីន វេសសេលស៍ (Katherine Vessels) និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម និង ការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និង យុត្តិធម៌អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្ដួចផ្ដើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University